ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ : ០០៥ / ០៧-ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## រូបសញ្ញាសាកលវិទ្យាល័យការពារជាតិ

## រដ្ឋមន្ត្រី ក្រសួងការពារជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើប្រាស់ច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការកែសំរួល បង្កើតផ្លាកសញ្ញាមួយចំនួនបំពេញបន្ថែមលើមាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពីការកែសម្រួលផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពត័ត្រយោង ឯកសណ្ឋានការងារលេខ៤ មួកបេរ៉េ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ៤ និងសញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យ លេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះ និងដំឡើងឋានៈវិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ

-តាមសំណើ របស់សាកលវិទ្យាល័យការពារជាតិ


1 8 JAN 2007

## សម្រេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតអោយប្រើប្រាស់រូបសញ្ញាសាកលវិទ្យាល័យការពារជាតិ ។

**ប្រការ ២ :** កំណត់រូបសញ្ញាសាកលវិទ្យាល័យការពារជាតិ ដូចខាងក្រោម :

**ក- សញ្ញានេះ** មានរាងជារង្វង់ លើផ្ទៃចន្លោះរង្វង់ទាំងពីរមានផ្កាយម្ខាងមួយ ចែកពាក់កណ្តាលរង្វង់ ដែលផ្ទៃខាងលើរលេចអក្សរខ្មែរ **សាកលវិទ្យាល័យការពារជាតិ** និងផ្ទៃខាងក្រោមអក្សរឡាតាំង NATIONAL DEFENSE UNIVERSITY ។ រង្វង់ខាងក្នុងមានផ្ទៃឆ្នូតពណ៌ខៀវពីរអមឆ្នូតក្រហម ( តំណាងឱ្យទង់ជាតិព្រះរាជាណាចក្រកម្ពុជា ) មានកាំភ្លើងវែងពីរដើមនៅលើស្លាបសត្វពីលើយុថ្កា ( តំណាងឱ្យទ័ពទាំងបីប្រភេទ) នៅកណ្តាលឆ្នូតពណ៌ក្រហមមានសៀវភៅបើកមួយ ( តំណាងឱ្យគម្ពីរ ក្បួនតម្រាការពារជាតិ និងការសិក្សារៀនសូត្រ ) ដែលផ្នែកខាងលើមានមកុដពណ៌មាស មានឆព្វណ្ណរង្សីចំនួន ១៥ ( តំណាង ឱ្យព្រះមហាក្សត្រ ) និងមានកួរស្រូវពីរកួរព័ទ្ធពាក់កណ្តាលខាងលើ ( តំណាងឱ្យការអភិវឌ្ឍន៍ ) ។

**ខ- ខ្នាត និងទំហំ :** រង្វង់ក្រៅមានអង្កត់ផ្ចិត ៨០ម.ម កាំភ្លើងមានប្រវែង ៥០ម.ម ស្លាបសត្វមានប្រវែង ៦៤ម.ម ពីចុងយុថ្កាម្ខាងទៅចុងម្ខាងទៀតមានប្រវែង៤៨ម.ម ទំហំសៀវភៅបើកមានប្រវែង ២៨ម.ម និងកំពស់ ១២ម.ម មកុដ និងឆព្វណ្ណរង្សីមានកំពស់ ១៦ម.ម កួរស្រូវមានកំពស់ ២៤ម.ម ។

**គ- រូបសញ្ញានេះ** សំរាប់ដាក់លើដៃអាវឆ្វេង "**ក្រណាត់**" និងនៅលើគម្របហោប៉ៅអាវស្តាំ "**លោហធាតុ**" នៃឯកសណ្ឋានលេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត ស្រោមលិខិត សញ្ញាប័ត្រ លិខិតបញ្ជាក់ការសិក្សា នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ និងនៅទីតាំងសាកលវិទ្យាល័យការពារជាតិ ។

( រូបសញ្ញាសាកលវិទ្យាល័យការពារជាតិ មាននៅក្នុងឧបសម្ព័ន្ធ )

**ប្រការ ៣ :** អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន និងមេបញ្ជាការ កងឯកភាពដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

នាយឧ.ផ្កាយមាស៥ ទៀ-បាញ់

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
  ( ដើម្បីជូនជ្រាប )
- ថ្នាក់ដឹកនាំក្រសួងការពារជាតិ
- ទីប្រឹក្សាក្រសួងការពារជាតិ
- អគ្គបញ្ជាការដ្ឋាន ខ.ភ.ម.
- ដូចប្រការ ៣
  ( ដើម្បីជូនជ្រាប និងអនុវត្ត)
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

(ឧបសម្ព័ន្ធ)

## សញ្ញាសំគាល់កងឯកភាព សាកលវិទ្យាល័យការពារជាតិ

◆ ◆ ◆ ◆ ◆

**ក- រូបភាព :** មានរាងជារង្វង់ លើផ្ទៃចន្លោះរង្វង់ទាំងពីរមានផ្កាយម្ខាងមួយ ចែកពាក់កណ្តាលរង្វង់ ដែលផ្ទៃខាងលើរំលេចអក្សរខ្មែរ **សាកលវិទ្យាល័យការពារជាតិ** និងផ្ទៃខាងក្រោមអក្សរឡាតាំង NATIONAL DEFENSE UNIVERSITY ។ រង្វង់ខាងក្នុងមានផ្ទៃឆ្នូតពណ៌ខៀវពីរអមឆ្នូតក្រហម មានកាំភ្លើងខ្វែងពីរដើមនៅលើស្លាបសត្វពីលើយុថ្កា នៅកណ្តាលឆ្នូតពណ៌ក្រហមមានសៀវភៅបើកមួយ ដែលផ្នែកខាងលើមានមកុដពណ៌មាស មានឆព្វណ្ណរង្សីចំនួន ១៥ និងមានកួរស្រូវពីរកួរព័ទ្ធពាក់កណ្តាលខាងលើ ។

**ខ- ខ្នាត និងទំហំ :** រង្វង់ក្រៅមានអង្កត់ផ្ចិត៨០ម.ម កាំភ្លើងមានប្រវែង៤០ម.ម ស្លាបសត្វមានប្រវែង ៦៤ម.ម ពីចុងយុថ្កាម្ខាងទៅចុងម្ខាងទៀតមានប្រវែង ៤៨ម.ម ទំហំសៀវភៅបើកមានប្រវែង ២៨ម.ម និងកំពស់ ១២ម.ម មកុដ និងឆព្វណ្ណរង្សីមានកំពស់ ១៦ម.ម កួរស្រូវមានកំពស់ ២៤ម.ម ។